# លក្ខណៈពិសេសនៃជាតិខ្មែរ



ត្រូវស្វែងយល់អំពីលក្ខណៈពិសេសនៃខ្មែរយើង...!

ដោយ : និស្សិត ម៉ៅ សុខា

# លក្ខណៈពិសេសនៃជនជាតិខ្មែរ

## ស្រាវជ្រាវដោយលោក ហៀន វណ្ណារ័ត្ន

## (ដកស្រង់ចេញពីទស្សនាវដ្ដី កម្ពុជសុរិយា ឆ្នាំទី៤៨ ព.ស.២៥៣៨ គ.ស.១៩៩៤)

ជនជាតិខ្មែរ ភាគច្រើនមានសម្បុរស្រអែម គឺមិនខ្មៅពេក មិនសពេក មានកម្ពស់មធ្យមប្រមាណ១៦០ស.ម. សម្បុរភ្នែកទ្រង់ខ្មៅ សក់រួញឬរួញអង្កាដី មិនជាត់មិនស្គម លលាដ៍ក្បាលមិនវែង មិនមូល គឺកណ្ដាល (Meso-cephalic) បបូរមាត់មិនក្រាស់ពេក មិនស្ដើងពេក។ លក្ខណៈដូច្នេះ យើងអាចប្រៀបធៀបស្រដៀងឬលក្ខណៈដូចពួកមនុស្សនៅលើកោះមេឡាណេស៊ី (Melanesia) តាំងនៅលើផ្ទៃសមុទ្រប៉ែកខាងកើត ខាងត្បូងនិងខាងលិចប្រទេសអូស្ត្រាលី (Australia)។ មេឡាណេស៊ី ប្រកបដោយកោះច្រើនណាស់ មានកោះនូគីនេ (New Guinea) ជាដើម មានប្រជាជនច្រើនអម្បូរ។ គេចែកជាក្រុមធំៗគឺ: Papuan, Negrid និង Melanesian។ ពាក្យថា Melanesia ជាពាក្យក្រិក ញែកបាន២ម៉ាត់: Melas (ខ្មៅ) និង Nesos (កោះ) រួមជា Melanesia ប្រែថា កោះមានមនុស្សសម្បុរខ្មៅ។ តែមនុស្សលើកោះដែលហៅថា មេឡាណេស៊ីនោះ មានពណ៌ខ្មៅល្មមទេ សក់រួញ បបូរមាត់និងលលាដ៍ក្បាលមិនធំមិនតូច។

ឯប្រជាជាតិខ្មែរសព្វថ្ងៃ ប្រើពាក្យថា មេឬម៉ែ។ អ្នកមានមុខតំណែងក្នុងឃុំស្រុក គេតែងហៅថា មេឃុំ មេស្រុក មេកន្ទ្រាញ មេបា មេធ្មប់ មេកង មេទ័ព។ល។ ប្រវត្តិខ្មែរពីអតីតៈបញ្ជាក់ឱ្យឃើញថា យកស្រីជាធំ គឺបូជាស្ត្រីភេទ ឧទាហរណ៍: ព្រះនាងរាជិនីឬលីវយី ជារាជិនីប្រមុខខ្មែរ សម័យផ្ដើមប្រវត្តិសាស្ត្រ។ បើយើងពិចារណាវប្បធម៌ជនជាតិមេឡាណេស៊ី ដូចពោលមកហើយនោះ ក៏ឃើញថាមានលក្ខណៈស្រដៀងគ្នាទៀត គឺជនជាតិមេឡាណេស៊ីនេះរាប់ពូជខាងម្ដាយជាគោល (Maternally) ក្នុងការបន្តពូជក្នុងគ្រួសារមួយៗ។ លោក សឺដេស (G. Coedes) បាន

នាំសម្ដីលោក Vanleur មកអាងក្នុងសៀវភៅរបស់លោកថា ពូជមនុស្សនៅលើផ្ទៃសមុទ្រដែលគេឱ្យឈ្មោះ Austronesoid នេះ សុទ្ធតែលើកម្ដាយជាធំទាំងអស់ (Matriachate)។

ជំនឿអ្នកតា ប្រជាជនខ្មែរសព្វថ្ងៃ មានជំនឿម្យ៉ាង យ៉ាងខ្ជាប់ខ្ជួនថា នៅតាមភូមិ ឃុំ ស្រុក ខេត្តនិងនគររបស់ខ្លួន មានវិញ្ញាណក្ខន្ធបុព្វបុរសរបស់ខ្លួន ដែលមានឈ្មោះថាអ្នកតា បីបាច់រក្សាទៅតាមជាន់ថ្នាក់។ អ្នកតាទាំងឡាយនោះ ចេះរៀបចំតំបន់ស្រុកទេស ហើយរើសចៅភ្នាក់ងារដែលមានបច្ចេកទេស ឱ្យទៅនៅប្រចាំ ដូចជា អ្នកតាព្រះឥសូរ, អ្នកតាព្រះនារាយណ៍, អ្នកតាដំងកើ ជាអ្នកចាំត្រួតត្រា រក្សាអាណាខេត្តប្រទេសកម្ពុជាទាំងមូល។ ឯនៅតាមខេត្ត គេប្រគល់តំណែងជូនដល់អ្នកតាឃ្លាំងមឿង តែនៅតាមស្រុកដោយច្រើន គេហៅតំណែងទៅតាមស្រុកដែលអ្នកតានៅ, ឧទាហរណ៍ៈ អ្នកតាបាណន់ (បាត់ដំបង) អ្នកតាពាមសីមា, អ្នកតាប (បប៉ៃលិន)។ល។ នៅតាមផ្ទះសម្បែង គេប្រគល់ឱ្យអ្នកតាមេភូមិ ដែលមានឈ្មោះថាព្រះភូមិ ជាអ្នករក្សាអាណាខេត្ត ត្រឹមបរិវេណភូមិប៉ុណ្ណោះ។ ក្នុងសៀវភៅព្រះរាជពិធីទ្វាទសមាស បានសន្និដ្ឋានតាមសេចក្ដីក្នុងច្បាប់ព្រះរាជក្រមហាឫសីបន្ទូលទុក លេខ គ.៥០ ថា មានពាក្យថា “អ្នកទេព្តា” ច្រើនអន្លើក្នុងបទបួងសួង។ ពាក្យ “អ្នកទេព្តា” នេះ អាចរួញទៅជាអ្នកតា។ ពាក្យនេះ ឃើញថាមិនអាចក្លាយទៅបានទេ ព្រោះនៅទំព័រទី១ លោកថា ពាក្យថា “អ្នកតា” ជាភាសាខ្មែរ គូគ្នានឹង “អ្នកដូន”។ យើងយកពាក្យថា “អ្នកតា” មកពិចារណាមើល តើដូចពាក្យថា “អ្នកទេពតា ទេ?” យើងក៏ឃើញថាៈ ពាក្យថា អ្នកតា ជាពាក្យខ្មែរសុទ្ធ ដូចលោកអាងមែន ប៉ុន្តែ ពាក្យថា អ្នកទេពតា ជាពាក្យកូនកាត់ ខ្មែរ+បាលី។ ម្យ៉ាងទៀត ខ្មែរមានពាក្យថា អ្នកដូន ក្លាយមកពី អ្នកទេពដូន បានឬអី? ឆ្លើយថា មិនអាចដូច្នេះបានទេ គឺពាក្យថា អ្នកតា ក៏ជាអ្នកតារបស់ខ្មែរ ឯពាក្យថា ទេពតា ក៏ជា ទេវតា របស់ឥណ្ឌាទើបត្រូវ។

ខ្មែរយើងរាប់អានអ្នកតា តាំងពីបុរាណកាលមក។ កំណត់កត់ហេតុចិនសម័យរាជវង្សធិន (ព.ស.៨០៨–៩៦២) បានពោលដល់ប្រទេសនគរភ្នំថា អ្នកស្រុកនគរភ្នំ គោរពរាប់អានខ្មោច ទេវតាណាស់ គេធ្វើរូបដំណែលដោយសំឫទ្ធិ។ ដល់ខ្មែរឡើងកាន់ភាពជាមហាអំណាចរវាងព.ស.១៣៥០–១៨៥០ ក៏ឃើញថានៅកាន់ខ្ជាប់អ្នកតានៅឡើយដែរ។

តាមកិច្ចការស្រាវជ្រាវ មានទស្សនៈយល់ឃើញអំពីរឿងអ្នកតា ដូចតទៅនេះ ÷

ប្រជាជនខ្មែរ តាំងពីបុរាណព្រេងនាយ មានការគោរពបូជារហូតដល់ឱ្យអភិសិទ្ធិផ្សេងៗក្នុងក្រុមរបស់ខ្លួន ឱ្យដល់វីរបុរសដែលបានបង្ហូរឈាមការពារអម្បូរនិងទីលំនៅនៃអម្បូររបស់ខ្លួន។ វីរបុរសដូចនេះ មានឈ្មោះថាជាអ្នកតស៊ូ។ ពាក្យថា “ត” នេះ មានន័យ២គឺៈ ១–បានដល់ន័យថា ភ្ជាប់, ២–បានដល់ន័យថា ការពារឬស៊ូ។ ពាក្យថា “ត” បើធ្វើឱ្យទៅជាករណនាម ទៅជា តំណ (បន្ត), តំណបើជានាមនាមដែលជាឈ្មោះវត្ថុឬមនុស្ស យើងមានពាក្យ ថ្ម (វត្ថុដែលតគ្នា) អ្នកត (គឺអ្នកតស៊ូ)។ តាមលំអានប្រពៃណីនិងរបៀបភាសាខ្មែរដូចជម្រាបមកនេះ ឃើញថា ពាក្យថា “អ្នកតា គួរវិវត្តន៍មកអំពី អ្នកត”។ ឯពាក្យមួយទៀតគឺ ពាក្យថា “តល្ល” ដែលធ្លាប់ប្រើពីបុរាណ សព្វថ្ងៃសរសេរថា “ដល់” បើធ្វើឱ្យទៅជានាមត្រូវថា “ត្នល់”។ សព្វថ្ងៃថា “ថ្នល់” (ផ្លូវដែលសន្ធឹងពីម្ខាងទៅដល់ម្ខាង)។ មនុស្សដែលយកដៃឱ្យទៅដល់អ្នកម្នាក់ទៀត ហៅថា អ្នកដល់ (អ្នកដាល់) តាមលំអាននេះឃើញថា ពាក្យថា “អ្នកត” គួរគូនឹងពាក្យថា អ្នកតល្ល (អ្នកដល់)។ អ្នកទាំងពីរនេះ សុទ្ធតែខ្លាំងពូកែទាំងអស់ គឺជាអ្នកតទល់នឹងសត្រូវ ដើម្បីស្រុកទេសរបស់ខ្លួន។ ពាក្យទាំងពីរម៉ាត់នេះ គួរក្លាយមកជា អ្នកតា អ្នកដូន ដូច្នេះ។

ប្រជាជនពួក Pigmoid, Negroid, Papuan ហើយនឹង Melanesian នៅលើកោះដែលហៅថា Melanesia នោះ តាមសេចក្ដីរាយការណ៍របស់លោក Roland

W. Force បានឱ្យដឹងថា ប្រមុខឬមេដឹកនាំក្រុមរបស់ខ្លួន ត្រូវតែជា "អ្នកតស៊ូ" ដ៏ល្បី ហើយមានឈ្មោះសំឡេងល្អ (prowess) ទើបត្រូវជ្រើសជាប្រមុខរបស់គេបាន។ ពួកអ្នកនៅម្តុំកោះនៃអាណាបរិវេណអូស្ត្រាលីនេះ និយមធ្វើរូបគោរព ព្រោះគេមានជំនឿក្នុងរូបគោរព (Totimic belief) នេះ យ៉ាងខ្ជាប់ខ្ជួន។ ខ្ញុំជឿជាក់ថា រូបគោរពដូច្នេះ គឺជារូបតំណាងវីរបុរសរបស់ពួកខ្លួនជាមិនខាន, ត្រង់នេះយើងគួរប្រៀបធៀបនឹងខ្មែរយើងដែលគេសាងរូបអ្នកតា ដើម្បីជាតំណាងវីរជនដែលតស៊ូដើម្បីការពារពូជឬទឹកដីរបស់ខ្លួន (សព្វថ្ងៃ យើងឃើញគេសាងរូបសំណាកអ្នកតាពូកែ សឹងគ្រប់ខេត្ត ប៉ុន្តែគេនិយមហៅថា អនុស្សាវរីយ៍ទៅវិញ)។

អំពីការសែនព្រេន បន់ស្រន់ តាមសេចក្តីរាយការណ៍របស់លោក Roland ដដែលនេះ បានបញ្ជាក់ថា "...គ្រឿងឧបករណ៍ប្រើក្នុងពិធី (បួងសួងថ្វាយដល់ខ្មោច) នោះ គេត្រូវត្រៀមយ៉ាងវិចិត្របញ្ចង់។ ក្នុងពិធីនេះ តែងតែមានការជប់លៀងនិងមានរបាំរាំរែកផង។ អ្នកកោះ Melanesia នោះ មានការខ្លាចវិញ្ញាណក្ខន្ធបុព្វបុរស, ខ្លាចខ្មោច, ខ្លាចស្ថានទី, រហូតដល់ខ្លាចរបស់ដែលគេមើលមិនឃើញ (ដូច្នេះ កាលបើមានអ្វីមួយ) កើតឡើង គេតែងតែបួងសួង បន់ស្រន់ថ្វាយនេះ-នោះ ដោយមានមេមត់ (Behaviour) ជាអ្នកបញ្ចូលរូប..."។

សេចក្តីរាយការណ៍ខ្លីរបស់លោក Roland ដូចជម្រាបមកនេះ គួរឱ្យជឿតែម្តងថា ប្រជាជាតិខ្មែរ គួរបានបន្តទំនៀមការសែនព្រេន លៀងអារក្ស ថ្វាយតង្វាយដល់ខ្មោចបិសាច ឡើងអ្នកតា មកពីពួក Melanesia ជាមិនខាន!

អំពីគ្រឿងអាវុធ អំពីការអាវុធ ធ្នូ ព្រួញ សរ ស្នា លំពែង។ល។ ខ្មែរយើងហាក់ដូចទើបតែឈប់ប្រើអាវុធបែបនេះ នៅពេលមិនយូរកន្លងមកហើយ។ ការប្រើអាវុធបែបនេះ ខ្មែរធ្លាប់ប្រើមកយូរយារណាស់ហើយ ព័ស្តុតាងដែលយើងសម្គាល់ក្នុងរឿងនេះ គេឃើញមានសេចក្តីក្នុងសិលាចារឹកចម្ប៉ា ថា កៅណ្ឌិន្យក្រោយពីបានលំពែងអំពីព្រាហ្មណ៍អស្វទមន កូនរបស់ទ្រោណៈហើយ ក៏គ្រវែង

ទៅដើម្បីជាគ្រឿងសម្គាល់ដល់កន្លែងតាំងក្រុងនាអនាគតកាល ស្រេចហើយបានអភិសេករួមរស់ជាមួយព្រះរាជបុត្រីស្តេចនាគ ព្រះនាមព្រះនាង សោមា...។ ព័ស្តុតាងក្នុងរឿងនេះមួយកន្លែងទៀត ហើយបានមកពីកំណត់កត់ហេតុរបស់រាជទូតចិនពីរគណៈប្រតិភូគឺៈ កាំងថៃនិងជូយិង ថា កៅណ្ឌិន្យ អាចមកពីប្រទេសឥណ្ឌាឬមាលេយ៍ បានយល់សប្តថា បុព្វបុរស (ទេវតាបុព្វបុរស) របស់ខ្លួន បានឱ្យធ្នូមកខ្លួន ហើយបានដឹកនាំខ្លួនឱ្យទៅដោយសារសំពៅជំនួញ។ ព្រឹកឡើងបានទៅកាន់ព្រះវិហារ (បូជនីយដ្ឋាន) នៅទីនោះ បានឃើញធ្នូនៅនឹងគល់ឈើរបស់បិសាច។ តមក បានដោយសារសំពៅមកដល់ក្រុងនគរភ្នំ ដោយអំណាចទេវឫទ្ធិស្តេចស្រីនៃនគរនេះ ព្រះនាម លីវ យី ចង់ប្លន់ដណ្តើមយកសំពៅ ដោយហេតុនេះ កៅណ្ឌិន្យ ទើបបាញ់សរពីធ្នូសិល្ប៍របស់ខ្លួនត្រូវសំពៅព្រះនាង លីវ យី។ ដោយការភិតភ័យ ទើបព្រះនាងញ៉មចាញ់។ កៅណ្ឌិន្យ បានយកព្រះនាងជាភរិយា...”។

នៅតាមផ្ទាំងជញ្ជាំងថ្មនៅអង្គរ យើងអាចសង្កេតឃើញពលទាហានឬព្រះរាជាកាន់ធ្នូឬលំពែងជាប់នៅដៃច្រើនណាស់ រាប់មិនអស់។

ខ្មែរមានអាវុធដូច្នេះ គួរជឿថាមានពូជមកពីពួកមនុស្សនៅតាមកោះនានានៃអូស្ត្រាលីដែរ ព្រោះមនុស្សដូចពោលមកនេះ មានប្រើធ្នូ ប្រសរ រហូតដល់សព្វថ្ងៃ។

ទិសខ្មោច គួរឱ្យសង្កេតថា ទិសផ្សេងៗ ដែលខ្មែរហៅសព្វថ្ងៃ ជាពាក្យខ្មែរសុទ្ធ គ្មានខ្ចីឬប្រឡំយកសម្តីជាតិណាមកប្រើទេ។ អំពីការសន្មតហៅទិសថាខាងជើង ខាងត្បូង ខាងកើតនិងខាងលិចដូច្នេះ អាចកើតឡើងដោយសារពិធីកប់ខ្មោច។ ខ្មែរពីបុរាណ មុនទទួលកាន់លទ្ធិពុទ្ធសាសនា គង់និយមការកប់សាកសពក្រោយពេលស្លាប់ទាំងអស់។ លុះដល់សព្វថ្ងៃ យើងក៏ឃើញថា ប្រជាជាតិនៅតែនិយមកប់សាកសពនៅឡើយ។

ឯទិសដែលខ្មែរខ្លាច មិនហ៊ានដេកបែរក្បាលទៅរកសព្វថ្ងៃគឺ ទិសខាងលិច (ជួនកាលហាក់ដូចជាមិនហ៊ានបែរក្បាលទៅខាងត្បូងផង) ប្រពៃណីដូច្នេះគង់មកអំពីពិធីកប់សាកសព គឺគេនិយមឱ្យក្បាលសពទៅទិសខាងលិចឬខាងត្បូង។ ឯហេតុផលដែលយើងអាង ហាក់ដូចជាថា ទិសខាងកើត បានដល់កំណើតដែលយើងកើតជាមនុស្ស លុះដល់យើងបាត់បង់ជីវិតទៅ ហាក់ដូចជាកំណើតមនុស្សលិចបាត់ទៅដែរ។ បើតាមទស្សនៈខ្ញុំផ្ទាល់ ខ្មែរបុរាណ ប្រហែលជឿថា ទិសដែលព្រះអាទិត្យរះ គឺជាកំណើតរបស់មនុស្ស ឯទិសដែលព្រះទិនករលិចទៅវិញនោះ ប្រៀបបាននឹងការចាកលោកនេះទៅវិញនៃមនុស្សម្នាក់ៗ។

ទស្សនៈខាងលើនេះ គ្រាន់តែព្រាងៗ ស្រពិចស្រពិល មិនច្បាស់លាស់ យើងអាចជឿថា ខ្មែរជំនាន់មុន អាចមានហេតុទូលំទូលាយជាងនេះទៅទៀតក៏សឹងបាន។ ហេតុដែលបុព្វបុរសខ្មែរយើងមានពិធីដូច្នេះ អាចមានទំនាក់ទំនងអំពីជំនឿខាងលទ្ធិ ដែលយើងបង្កើតយូរណាស់ មុនទទួលកាន់ព្រះពុទ្ធសាសនាម្ល៉េះ។

តាមលទ្ធផលដែលអ្នកប្រាជ្ញបុរាណវិទ្យា (Archeologist) បានពិនិត្យរកទិសសាកសព ដែលគេបានជីកឃើញនៅយុគណេអូលីទិច (Neolithic) នៅលើផ្ទៃដីប្រទេសថៃ មានលក្ខណៈជាភាគរយ ដូចតទៅនេះ ៖

–សពបែរក្បាល់ទៅទិសខាងត្បូងមាន២១,៩%

–សពបែរក្បាលទៅទិសខាងលិចឆៀងខាងជើងមាន៣៤,១%

–ឯទិសក្រៅពីនេះ មានលទ្ធផល២-៣%ប៉ុណ្ណោះ។

ជំនឿខ្មែរអំពីទិសខ្មោច ដូចជម្រាបមកនេះ ក្រៅអំពីមានលក្ខណៈដូចគ្នានឹងសាកសពដែលគេបានជីកឃើញសពមនុស្សជំនាន់ Neolithic ហើយ ក៏នៅមានលក្ខណៈដូចគ្នានឹងពួកមនុស្សដែលលោក ពីវេត P. Pivet ហៅថា “ពួកសមុទ្រ” (Oceanien)។ ពួកសមុទ្រនេះ ខ្ញុំសម្តៅយកមនុស្ស ដែលលោក ជីន យូឌីន បានពោលទុកក្នុងសៀវភៅរបស់លោក (Foot Note) ថា គឺជាពួកឥណ្ឌូណេស៊ី

ចាកន (Jakan) មេនត្រា (Mentra) សេមាំង (Semung) និងសាកៃ (Sakai)។ នេះជាឧបករណ៍ក្នុងការប្រៀបធៀបៈ

ជាតិឥណ្ឌូណេស៊ី និយមកប់ខ្មោចឱ្យបែរក្បាលទៅទិសខាងលិច ព្រោះគេជឿថា នៅទិសនេះមានរូងដែលអាចចុះទៅកាន់ពិភពបាតាលបាន –រូងនេះជាផ្លូវដែលព្រះអាទិត្យចុះទៅបញ្ចាំងរស្មីនៅពិភពបាតាល ក្រោយដែលបញ្ចាំងលើមនុស្សលោករួចហើយ។ ជួនកាល កប់ខ្មោចនៅពេលព្រះអាទិត្យកំពុងតែអស្តង្គត ដើម្បីឱ្យព្រះអាទិត្យជួយនាំវិញ្ញាណក្ខន្ធទៅផង។

ពួកអ៊ូស៊ុន (Ousun) ក៏និយមឱ្យសពបែរក្បាលទៅទិសខាងលិចដែរ ព្រោះមានជំនឿថា ពិភពបាតាលនៅទិសខាងលិច។

ពួកមេនត្រា (Mentra) និយមកប់ខ្មោចដោយឱ្យសាកសពអង្គុយឬឈរបែរមុខទៅខាងលិច (ពិធីនេះទេដឹង ដែលខ្មែរអ្នកមានឋានន្តរស័ក្តិខ្ពស់ បានទទួលយក... ព្រោះដោយច្រើន ខ្មែរឱ្យសពអង្គុយក្នុងកោដ្ឋ...)។

ពួកសេមាំង នៅប្រទេសម៉ាឡេស៊ី មានជំនឿថា មនុស្សស្លាប់ហើយវិញ្ញាណក៏នឹងធ្វើដំណើរទៅកាន់ស្រុកដែលមានដើមស្រល់ (Screw Pines and Match-Pines) នៅទីនោះ មានរូងដែលជាផ្លូវនៃព្រះអាទិត្យគោចរក្រោយថ្ងៃលិច។

ពួកនេគ្រីតូស (Negritos) និងពួកសាកៃ ដែលនៅលើជ្រោយម៉ាឡេស៊ី ក៏និយមកប់សាកសពបែរទៅខាងលិចដែរ ព្រោះមានជំនឿថា ទិសនេះជាផ្លូវដែលខ្មោចដើរ។

រួចមកហើយនេះ យើងកំពុងតែស្រាវជ្រាវរកដាន ដើម្បីឱ្យដល់ចំណុចដែលថា “តើ ខម និង ខ្មែរ ជាជាតិតែមួយឬផ្សេងគ្នា?”

តាមលក្ខណៈផ្លូវកាយនិងវប្បធម៌នៃសង្គមដែលស្រដៀងឬដូចគ្នា រវាងជនជាតិខ្មែរនិងពពួកមនុស្សបុរាណ ដែលសព្វថ្ងៃរស់នៅលើផ្ទៃមហាសមុទ្រប៉ាស៊ីហ្វិកនិងតាមព្រៃព្រឹក្សាជ្រៅក្នុងអាស៊ីអាគ្នេយ៍នោះ ឃើញថា ល្មមវិនិច្ឆ័យ

រកតំណបបាន ប្រជាជាតិខ្មែរសព្វថ្ងៃ ភាគខ្លះមានពូជតំណអម្បូរពីជនជាតិដែលសព្វថ្ងៃ មានជីវភាពរស់នៅស្រដៀងយុគថ្មនៃព្រេងនាយ។ ពពួកមនុស្សបុរាណអស់នោះ គឺជាមនុស្សដែលមានឈ្មោះថា អូស្ត្រូឡូអ៊ីត (Austroloid) មេឡានេសូអ៊ីត (Melanesid)។ ប្រជាជនដែលហៅថា Astroloid និង Melanesoid នោះបានដល់អម្បូរជាតិនានាដែលសព្វថ្ងៃហៅថា Papuan; Negritos; Melanesian; Semung។ល។ អម្បូរមនុស្សដូចពោលមកនេះឯង បានចោលគម្រោងឆ្អឹងនិងគ្រឿងប្រើប្រាស់រាត់រាយដេរដាសពាសពេញលើភាគទាំង៥ នៃអាស៊ីអាគ្នេយ៍យើង។ តមក អ្នកប្រាជ្ញបុរាណវិទ្យា (Archeologist) បានរកឃើញ ហើយឱ្យយើងជ្រាបថា ពពួកមនុស្សអស់នេះហើយ ដែលធ្លាប់ឃឹតយកដែនដីអាស៊ីអាគ្នេយ៍នេះ ជាទីអាស្រ័យរហូត តាំងពីយុគថ្មចាស់ដែលហៅថា យុគប៉ាលីអូលីទីក (Palaeolithic perriod) ដល់យុគថ្មថ្មី ដែលហៅថា Neolithic ដូចជម្រាបមកតាមលំដាប់ស្រាប់ហើយ។ ជំនាន់យុគថ្មចាស់និងថ្មកណ្តាល ឃើញថាមនុស្សបុរាណមិនបានសាងអារ្យធម៌ទុកច្រើនទេ, គេបានរកឃើញត្រឹមតែគ្រឿងប្រើប្រាស់ដែលគេធ្វើពីថ្ម ត្បូង ឆ្អឹងសត្វ ព្រមទាំងវប្បធម៌ម្យ៉ាង ដែលហៅថា Megalith និង Microlith គឺជាវប្បធម៌ថ្មតម្រៀបឬថ្មដូរ, កូនចៅមនុស្សបុរាណពួកនេះ មាននៅទូទៅសព្វថ្ងៃ។ លោក James Hornell បានមានប្រសាសន៍ថា ៖ "ពួកមនុស្សដែលមានដើមកំណើតលើជ្រោយឥណ្ឌូចិនឬតាមកោះនានានេះ បានផ្សាយទៅនៅពាសពេញលើផ្ទៃដី ដែលហៅថាឥណ្ឌាសព្វថ្ងៃនេះ មុនសម័យកាលចូលមករុករាននៃជនជាតិអារ្យៈ"។

សេចក្តីនេះ សឱ្យឃើញថា ពួកមនុស្សបុរាណដែលជាពូជខ្មែរមួយភាគនេះ ធ្លាប់បានចូលទៅនៅពេញប្រទេសឥណ្ឌា មុនយុគដែលជាតិអរិយកៈចូលមករុករាននៅសម័យដែលប្រទេសឥណ្ឌា មិនទាន់បានកើតជាប្រទេសនៅឡើយម្ល៉េះ។ នៅសម័យនោះ បើតាមលក្ខឋានខាងព្រះពុទ្ធសាសនាប្រាប់ថា ពួក

ជនដែលនៅមុនជាតិអរិយកៈនេះ មានឈ្មោះថាមិលក្ខៈ គឺជនមិនមានស៊ីវិល័យ ឬមនុស្សថោកទាប។ ពេលនោះ ពូជខ្មែរត្រូវជនអរិយកៈបង្អាប់ណាស់ គេស្អប់ មិនហ៊ានឱ្យចូលរួមសង្គមរបស់គេទេ ព្រោះពួកអរិយកៈប្រកាន់ជាតិ ប្រកាន់ថ្នាក់ណាស់ (ព្រះពុទ្ធជាម្ចាស់របស់យើង ព្រះអង្គមិនពេញព្រះទ័យនឹងអំពើឈ្លានពានមនុស្សនៃជាតិអរិយកៈទេ)។

ព័ស្តុតាងដែលឱ្យឃើញម្យ៉ាងទៀតថា ពួកមនុស្សអម្បូរ Austro Asiatic បានធ្លាប់នៅលើដី ដែលសព្វថ្ងៃហៅថាឥណ្ឌានោះ គឺគេបានជួបគ្រឿងប្រើប្រាស់ដែលហៅថា Shouldered celts ឬ Shouldered Tenen គឺគ្រឿឧបករណ៍ជាថ្មមានលក្ខណៈដូច "ដឹងមានស្មា" ជារបស់ប្រចាំពួក Austro Asiatic។ យុគ Neolithic នេះនៅពាសពេញត្រង់ទិសជ្រុងខាងជើង ឆៀងខាងកើតនៃផ្ទៃដីប្រទេសឥណ្ឌា និងប៉ែកខាងជើងប្រទេសចិន ព្រមទាំងមានទួទៅនៅលើផ្ទៃដីភាគកណ្តាលនៃអាស៊ីអាគ្នេយ៍។ លោក R.C.Majumdar អ្នកប្រាជ្ញល្បីឈ្មោះម្នាក់ បានពោលថា ពួក Dravidian ឬដែលហៅថាអារ្យជននេះ បានចូលរុកកានដែនដី ដែលសព្វថ្ងៃមានឈ្មោះថាឥណ្ឌានេះ ពីទិសខាងត្បូងឆៀងខាងលិច ជាហេតុរុញឱ្យពូជមនុស្សដើមនៅឥណ្ឌាពីមុននេះ ទៅនៅឥណ្ឌាប៉ែកខាងកើតនិងខាងត្បូងទៅវិញ។

លុះចំណេរកាលតមក ពួកមនុស្សដែលត្រូវពួកអរិយកៈបណ្តេញនេះ បាននាំគ្នារត់គៀសខ្លួនទៅនៅអាស៊ីអាគ្នេយ៍ ដោយបាននាំអារ្យធម៌ជំនាន់ដើមរបស់ខ្លួនជាប់មកផង។

ដល់ត្រង់នេះ សូមបញ្ជាក់ថា ពួកមនុស្សដែលហៅថាអម្បូរ Austro Asiatic នៅប៉ែកខាងឥណ្ឌា បានរត់មកនៅរួមជាមួយ Austro Asiatic ដូចគ្នាដែលនៅស្រេចហើយលើផ្ទៃដីអាស៊ីអាគ្នេយ៍នេះ។ ប៉ុន្តែពួកខាងក្រោយនេះ យើងនៅមិនទាន់ដឹងថា ជាអម្បូរជាតិណា, មកពីប៉ុន្មានឆ្នាំហើយនៅឡើយទេ។

រឿងនេះ យើងគួរប្រគល់ឱ្យលោក Eric Seidenfaden ដែលលោកបាន

មានប្រសាសន៍ក្នុងសៀវភៅមួយរបស់លោក ដែលបានប្រែជាភាសាថៃ ឈ្មោះ ជាតិវង្សវិទ្យា (ឆាតិវង្សវិទយ៉ា) ២៥១៩ ទំព័រ៧-៨, សេចក្តីថាៈ “ប្រមាណ៣៥០០ ឆ្នាំមកហើយ ជនជាតិដែលនិយាយភាសា Austro Asiatic អម្បូរមន-ខ្មែរ បាននាំគ្នាភៀសខ្លួនពីឥណ្ឌាប៉ែកខាងជើង មកនៅអាស៊ីអាគ្នេយ៍នេះ។ អម្បូរមន-ខ្មែរ។ . ឯឆ្នាំនោះ គេប្រមាណ៣៥០០ ឆ្នាំមុននេះ។

ដូច្នេះ ជំនឿកាលពីយូរណាស់មកហើយ ដែលថាខ្មែរដើម គឺជាតិឥណ្ឌា នោះហាក់ដូចជាខុស គួរមានពាក្យស្លោកថ្មីថា ឥណ្ឌាដើម គឺជាតិខ្មែរទៅវិញ ទើបហាក់ដូចត្រូវល្អជាង!

តទៅនេះ យើងត្រូវរកទីកន្លែងដែលអម្បូរមន-ខ្មែរ ពីសម័យ៣៥០០មុននេះ បានមកនៅលើទឹកដីអាស៊ី។ តែសូមយល់ថា មុនយុគដែលអម្បូរមន-ខ្មែរពីដែនដីដែលហៅថាប្រទេសឥណ្ឌាសព្វថ្ងៃមកអាស៊ីអាគ្នេយ៍នោះ មានមនុស្សជាបុព្វបុរសមន-ខ្មែរ បាននៅស្រេចអស់ហើយ ពួកនេះបើយើងសម្គាល់ទៅតាមលក្ខឋានបុរាណវត្ថុ ដែលជីកឃើញនៅ បានឆៀង (នឹងជម្រាបតទៅនៅយុគលោហៈ) បានឱ្យដឹងថា ពួកមនុស្សដែលនៅអាស៊ីអាគ្នេយ៍ ពិសេស គឺត្រង់ភូមិភាគផ្នែកកណ្តាលនៃអាស៊ីអាគ្នេយ៍ នៅភាគឦសានថៃនិងប្រទេសលាវ មានវប្បធម៌ខ្ពស់ណាស់ទៅហើយ។

ដើម្បីជាប្រយោជន៍ក្នុងការស្រាវជ្រាវអំពីកន្លែង ដែលមន-ខ្មែរ មកនៅនោះ យើងត្រូវអាងឯកសារដែលជាប្រយោជន៍ក្នុងរឿងនេះ ហើយសឹមយើងសរុបយកន័យខ្លះមកនិយាយ។

តទៅនេះ យើងងាកមកពិចារណាអំពីភូមិភាគដើមកំណើត មន-ខ្មែរ នៅភូមិភាគខាងត្បូងភ្នំហិមាល័យ ដូចតទៅៈ

ភ្នំហិមាល័យ (Himalayas) ជាភ្នំធំ មានជួរវែងអន្លាយ ប្រចាំអាស៊ីភាគកណ្តាល តាំងនៅរវាងប្រទេសទីបេត៍ (Tibet) ឥណ្ឌានិងប៉ាគីស្ថាន (Pakistan)។ ជួរ

ភ្នំដ៏វែងអន្លាយនេះ បើវាស់ពីទីដើមកំណើតទន្លេហិណ្ឌូ (Indus) ដែលនៅប៉ែកខាងជើង ជួរភ្នំខាងត្បូងឆៀងខាងលិចប្រទេសទីបេត៍ត្រង់មុំភ្នំកៃលាស (Kailas) មកដល់ទីដើមកំណើតទន្លេព្រហ្មបុត្រ (Brahmaputra) ដែលមានពីកើតនៅត្រង់ជួរភ្នំហិមាល័យ ខាងកើតឆៀងខាងលិចប្រទេស មានប្រវែង២.៤០០គីឡូម៉ែត្រ មានកំពូលខ្ពស់៨.៨៨២ម៉ែត្រ។ កំពូលភ្នំទាំងឡាយនេះ មានលក្ខណៈធំខ្ពស់ស្កឹមស្កៃ តាំងនៅខាងត្បូងវាលធំទីបេត៍។ នៅប៉ែកខាងជើងនៃភ្នំធំៗនេះ គឺជួរភ្នំ Kun-Lun ដែលតាំងនៅក្នុងអាណាខេត្តប្រទេសទីបេត៍។

នៅទិសខាងជើង បន្ទាប់ពីជួរភ្នំយក្សនេះ មានកន្លែងធំៗពីរកន្លែង ដែលយើងគួរយកមកពិចារណានូវដើមកំណើតអម្បូរជាតិយើងៈ កន្លែងទី១ គឺប៉ាមីរ (Pamir) ទី២ គឺកស្មីរ (Kashmir)។

Pamir: ឈ្មោះកន្លែងនេះ អ្នកស្រុកនៅទីនោះ ហៅថា Bami (គួរឱ្យសន្និដ្ឋានថា តាមច្បាប់កម្លាយភាសានៃនិរុត្តិសាស្ត្រ “Philology” ថាមកពីពាក្យថាឧប្បមេរុ បានដល់ទីខ្ពស់បន្ទាប់ពីភ្នំសុមេរុ) ជាភូមិភាគតាំងនៅលើខ្នងជួរភ្នំចោតសន្លឹម (Lofty mountains region) ឬម្យ៉ាងទៀត គេហៅថាដំបូលលោក (The roof of the world) ផ្ទៃទីឧប្បមេរុនេះ ភាគច្រើនតាំងនៅក្នុងសហភាពសូវៀត (រុស្ស៊ី) ភាគតូចពីរទៀត តាំងនៅលើផ្ទៃដីចិននិងអាហ្វហ្គានិស្ថាន (Afghanistan)។

ជួរភ្នំខ្ពស់ៗទាំងឡាយ ដូចជា Himalaya, the Kara Koram, the Kunlun។ល។ បានមកជួបគ្នានៅទីនោះ ជាហេតុឱ្យមានឈ្មោះថា ប៉ាមីរក្នុត (Pamir knot) នៅត្រង់ខាងលិចឧប្បមេរុ ជាប់នឹងភ្នំហិមាល័យប៉ែកខាងត្បូង គឺស្រុកកស្មីរ (Kashmir)។

Kashmir: ភូមិភាគនេះ តាំងនៅខាងជើងរដ្ឋបញ្ជាប់ (Punjab) ខាងកើតជាប្រទេសទីបេត៍, ចិនខាងត្បូង គឺផ្ទៃដីប្រទេសឥណ្ឌា ខាងលិចជាប់ប្រទេសប៉ាគីស្ថាន, ខាងជើងទល់ប្រទេសអាហ្វហ្គានិស្ថាននិងចិន មានទំហំដី៨៤.៤៧១ គារាងម៉ៃល៍ឬ១៣៥.១៣៣គ.ម.[២]។

ពាក្យ Kashmir នេះ សន្និដ្ឋានថាជាពាក្យតែមួយនិងពាក្យថា កស្មីរ ដែលមានប្រាកដក្នុងអដ្ឋកថាបាលី ភូមិវគ្គនៃព្រះពុទ្ធសាសនា ក្នុងកថានេះថា កស្មីរជានគរមួយ ក្នុងចំណោម២១នគរ ដែលព្រះពុទ្ធកាលទ្រង់មានព្រះជន្មគង់នៅបានទ្រង់ផ្សាយសាសនាព្រះអង្គទៅដល់។

ភូមិភាគកស្មីរនេះ កាលពីព្រេងនាយយូរណាស់មកហើយ គង់នៅដាច់ពីផ្ទៃដី ដែលហៅថា ជម្ពូទ្វីប។ ដែលថាដូចនេះ ព្រោះអ្នកប្រាជ្ញខាងធរណីសាស្ត្រ (Geologist) និងអ្នកប្រាជ្ញបុរាណសាស្ត្រ (Archeologist) ថា ក្រោយជំនាន់លិចទឹកកកប្រមាណ១០០.០០០ឆ្នាំ អាណាបរិវេណដែលតាំងនៅតាមដងស្ទឹងមេគង្គ (គឺចាប់តាំងពីទល់ដែនបញ្ជាប់ ដែលនៅខាងជើងរហូតដល់ផ្ទៃដីអស្សាំ) គង់ជាទន្លេ ព្រោះគេមិនអាចរកឃើញវត្ថុចំណាស់ក្នុងយុគ ប៉ាឡេអូលីទិក (Palaeolithic) សោះ។

បើដូច្នេះ ឃើញថាប្រទេសឥណ្ឌានៅជំនាន់នោះ គង់បែកជាពីរផ្នែកគឺអាណាបរិវេណប៉ែកខាងជើងទន្លេគង្គា ដែលរាប់ចាប់ពីរដ្ឋបញ្ជាប់ដល់កស្មីរមួយផ្នែកហៅថា ឧត្តរនិងប៉ែកខាងលិចឆៀងខាងត្បូងនៃភូមិភាគទន្លេគង្គា តាំងពីរដ្ឋពិហារ រហូតដល់ជាប់ផ្ទៃសមុទ្រ មួយផ្នែកទៀត ហៅថា កោះព្រីងឬជម្ពូទ្វីបដូច្នេះ។

ត្រង់នេះយើងឃើញថា អាណាបរិវេណត្រង់បញ្ជាប់និងកស្មីរ ជាភូមិភាគមានផ្ទៃដីដោយឡែក។ ក្នុងគម្ពីរព្រះអភិធម្មបានប្រាប់ថា នៅសម័យបុរាណមាន៤ទ្វីបៈ ឧត្តរកុរុទ្វីប, បុព្វវិទេហទ្វីប, អមរគោយានទ្វីបនិងជម្ពូទ្វីប។ ដូច្នេះយើងឃើញថា ក្នុងទ្វីបទាំង៤នេះ មានទ្វីបមួយនៅប៉ែកខាងជើង ឈ្មោះថា កុរុ (ឧត្តរ-កុរុ=កុរុ នៅខាងជើង)។ ក្នុងមហាសតិបដ្ឋានសូត្រ ក៏បានប្រាប់ថា ស្តេចចក្រពត្តិព្រះនាម មន្ធាតុរាជ ធ្លាប់នាំបរិវារដែលតាមស្តេចដែលមកពីទ្វីបទាំង៣ ដូចពោលនោះ មកតាំងនៅទាំង៣កន្លែងលើប្រទេសឥណ្ឌា គឺពួកដែលនាំមកអំពីឧត្តរកុរុ ឱ្យតាំងស្រុកនៅត្រង់កុរុ (កុរុខាងជើង) ពួកមកពីបុព្វវិទេហទ្វីប ឱ្យតាំង

នៅលើផ្ទៃដីទេហរដ្ឋ ពួកមកពីអមរគោយានទ្វីប ឱ្យតាំងនៅលើផ្ទៃដីដែលហៅថា អមរន្តៈ។

ពាក្យថា កេសមីរ (Kashmir) និងកស្មីរ ជាពាក្យតែមួយពិតប្រាកដ តែយើងសង្ស័យថា ពាក្យថា កស្មីរ នេះ ជាពាក្យតែមួយនឹង កុរុ បានឬទេ? តាមព័ស្តុតាងបានចង្អុលពីលើមក ដូចបានជម្រាបមកនេះ ឃើញថាជាភូមិភាគតែមួយជាមួយគ្នា គឺនៅត្រង់ភាគខាងជើងនេះម្យ៉ាង ម្យ៉ាងទៀត តាមកម្លាយភាសាដែលរេចរឹលរាប់ពាន់ឆ្នាំមកនេះ ឃើញថា ពាក្យទាំងពីរម៉ាត់នេះ ច្បាស់ជាក្លាយពីមួយមកមួយបាន ឧទាហរណ៍ ពាក្យដែលរេចរឹលដូច្នេះ គឺ ឧប្បមេរុ អ្នកស្រុកនៅទីនេះថា បាមីរ (Bamir) អង់គ្លេសសរសេរថា Pamir (ពាមីរ), បារាំងសរសេរថា Palmyr (ពាលមីរ) ឯពាក្យថា សុមេរុ អភិធម្មថា សិនេរុ ខ្មែរថា ភ្នំព្រះស្មេរុ សៀមថា ធុងព្រះមេន (វ៉ាលមេរុ) ដូច្នេះជាដើម ទើបសូមសរុបថា Kasimir កស្មីរ និងកុរុ ជាពាក្យតែមួយ។

ពីសម័យបុរាណ គឺអាចនៅក្នុងសម័យដែលមានទន្លេខ័ណ្ឌកណ្ដាល រវាងជម្ពូទ្វីបនិងភ្នំហិមាល័យនេះ សម័យនោះគឺជាសម័យមុនសាសន៍អរិយកៈចូលរុករានឥណ្ឌា ពួកអ្នកកោះជម្ពូទ្វីប មិនដែលមាននរណាហ៊ានឆ្លងទៅត្រើយម្ខាងសោះ ព្រោះទន្លេកាលណោះធំណាស់ បើមាននរណាបានឆ្លងទៅ គង់ស្លាប់គ្មានជីវិតត្រឡប់មកវិញបាន ពួកអ្នកជម្ពូទ្វីបបានត្រឹមតែមើលឃើញកំពូលភ្នំហិមាល័យខ្ពស់កប់ពពកដូច្នេះ អាចគង់គិតថា ភ្នំខ្ពស់អស់នោះ សុទ្ធតែជាទីនៅនៃពួកអ្នកមានឫទ្ធិចេស្ដាបារមីខ្ពស់ ទើបពួកគេនាំគ្នាយល់ឃើញថា នៅលើភ្នំខ្ពស់ៗនោះ សុទ្ធតែទីនៅរបស់ពួកអ្នកមានឫទ្ធី។ កំពូលភ្នំដែលខ្ពស់ជាងគេនោះ គេឱ្យឈ្មោះហៅថា មេរុរាជ មានស្រះអនោតត្ត ដែលមានកំពែងកែវ៧ជាន់ មានកំពង់មុជទឹក៤, កំពង់អស់នោះ សម្រាប់ពួកអ្នកវិសេស ដូចជា មាណព, កុម្ភណ្ឌ, គន្ធព្វ, អសុរ, វិទ្យាធរ, កិន្នរ, គ្រុឌ, ហើយនឹងពួកជដិល។ រីឯភ្នំដែលមានកម្ពស់ទាបចុះ

មកតាមលំដាប់ (ត្រង់ដែលយើងហៅថា ឧប្បមេរុ) នោះ មានឈ្មោះខុសគ្នា មាន ៧ជួរ។ ជួរមួយៗ មានឈ្មោះដូចតទៅគឺៈ សុទស្សនៈ, ករវិកៈ, ឥសិន្ធរៈ, យុគន្ធរៈ, នេមិន្ធរៈ, វិនតកៈ, អស្សកណ្ណៈ។ ក្នុងរវាងចន្លោះភ្នំមួយៗ មានទន្លេខ័ណ្ឌ មានឈ្មោះដូចគ្នាថា សីទន្តរ ទាំងអស់ ទន្លេអស់នោះមានសរសៃល្អិតណាស់ សូម្បីតែសរសៃតូចមួយរបស់សត្វក្ងោក ក៏អាលិចទៅបាន។

ឯដងភ្នំដែលទាបជាងគេឬដែលមានផ្ទៃរាបល្មមនោះ ជាទីនៅរបស់អសុរៈ, យក្ស, វិទ្យាធរ, គន្ធព្វឬពួកអមនុស្ស។ ពាក្យថា អសុរៈ គួរបានដល់ជនជាតិដែលគ្មានសេចក្តីក្លាហាន គឺមិនអាចតស៊ូ។ បើពិចារណាតាមប្រវត្តិសាស្ត្រឥណ្ឌា តាមគម្ពីរព្រះវេទ ក៏ឃើញថាពួកជនជាតិ អរិយកៈ មានចូលមកវាយពួក មិលក្ខៈ ពីទិសខាងជើងឆៀងខាងត្បូងនៃតំបន់ដែលហៅថាកស្មីរដែរ។ ពួកអ្នកស្រុកដើមគឺពួកមិលក្ខៈ ដែលពួកអរិយកៈ បង្អាប់ថាជាទាសៈទស្សនេះ បានចាញ់ដៃពួកអរិយកៈ ហើយនាំគ្នារត់មកនៅរាត់រាយក្នុងភូមិភាគដែលហៅថា ទក្សិណរធ-សោល (ខាងត្បូង)។ សេចក្តីនេះ ឃើញថាត្រូវនឹងទស្សនៈលោកអ្នកប្រាជ្ញប៉ែកខាងបុរាណសាស្ត្រនិងប្រវត្តិសាស្ត្រ ដូចពោលមកថា ពួកអម្បូរមន-ខ្មែរ បាននាំគ្នារត់មកពីភាគខាងជើងភ្នំហិមាល័យ ហើយបានមកនៅភាគខាងត្បូង រហូតដល់អាស៊ីអាគ្នេយ៍យើងនេះ។

ដល់មកត្រង់នេះ ខ្ញុំសូមសរុបសេចក្តីថា ពាក្យថា កុមេរុ អាចក្លាយទៅជា

{ កុរុ / កស្មីរ / Kashmir } បានហើយ បើយើងចាប់សេចក្តីពាំស្តុតាងទាំងឡាយ ដូចពោលមក

ហើយនេះថា អម្បូរមន-ខ្មែរ បានមកពីខាងជើងភ្នំហិមាល័យ ដូច្នេះមែន ក៏ឃើញថា តំបន់ខាងជើងភ្នំហិមាល័យ គួរជារដ្ឋកស្មីរ។ ពាក្យថា កស្មីរ និងពាក្យថា ខ្មែរ នេះ ស្រដៀងគ្នាណាស់ គួរឱ្យចាប់អារម្មណ៍យ៉ាងសមហេតុផលថា

ពាក្យថា កស្មីរ ស្រដៀងនឹងពាក្យថា កមីរ។ ពាក្យ កមីរ នេះ មានប្រាកដនៅក្នុងសិលាចារឹកចាម (ដូចធ្លាប់អាងមកពីមុនៗស្រាប់ហើយ) ពួកទូតចិន ក្នុងសម័យរាជវង្សសុង (Song period) បានមកស្រុកខ្មែរក្នុងសម័យកណ្ដាលនៃគ្រិស្តសត-វត្សរ៍ទី៧ បានហៅខ្មែរថា កិមិ (Ki-mir) ដូច្នេះឬដែលចិនកន្ដាំង ហៅថា កិមិត។

ពាក្យថា កមីរ ក្នុងសិលាចារឹក មានលក្ខណៈជិតដូចពាក្យថា កស្មីរ ជាទីបំផុត ឃើញពាក្យថា កមីរ នេះ គង់មានកម្លាយរេចរឹលដូចពាក្យឯទៀតដែរ។ តាមប្រវត្តិសាស្ត្រគ្រប់មជ្ឈដ្ឋាននៃអ្នកប្រាជ្ញប្រាប់ថា បុព្វបុរសជាតិ កមីរ នេះមកពីឥណ្ឌា។ ដូច្នេះ បើអ្នកប្រាជ្ញខ្មែរ ចិននិងអឺរ៉ុប បានទទួលស្គាល់ថា កមីរ នេះគឺជាតិខ្មែរនោះឯងហើយ យើងក៏គួរទទួលថា ពាក្យថា "ខ្មែរ" នេះ គឺជាពាក្យតែមួយនឹងពាក្យថា "កស្មីរ" នេះដែរ។

ឥឡូវនេះ គឺបានសេចក្ដីកាន់តែច្បាស់ហើយថា ជនជាតិដែលភៀសខ្លួនមកពីខាងជើងភ្នំហិមាល័យ ក៏គឺជនជាតិអម្បូរខ្មែរតែម្ដង ព្រោះយើងសម្អាងទៅតាម ៖

១–មិត្តអ្នកប្រាជ្ញ

២–ប្រវត្តិសាស្ត្រយុគថ្ម

៣–ទីស្ថាន

៤–កម្លាយពាក្យរេចរឹល ផ្លូវនិរុត្តិសាស្ត្រ (Philology)

កម្លាយពាក្យនេះ មានដូចតទៅៈ ខ្មែរ ខ្មេរ ក្មេរ កមីរ កុរុ កុមេរុ ដូច្នេះ។

ខ្ញុំមានទស្សនៈដូច្នេះ គឺគ្រាន់តែលើកយកមកជូនអស់លោកនិងប្អូនៗអនុជនពិចារណា ដើម្បីជាផ្លូវរកដើមកំណើតប្រវត្តិសាស្ត្រជាតិតែប៉ុណ្ណោះ។

តាមទស្សនៈដែលសមគួរទៅតាមហេតុផលខាងលើនេះ តើអស់លោកនិងប្អូនៗ យល់ថាតើ មននិងខ្មែរ អ្នកណាកើតមុន? តាមទស្សនៈខ្ញុំ,ខ្ញុំសូមជម្រាបយ៉ាងផ្ដាច់ព្រាត់ថា កាលដើមឡើយ ពាក្យថា មន មិនទាន់មានប្រាកដទេ។ មនឬ

ជាតិដែលនិយាយភាសាអម្បូរខ្មែរ-មនទាំងឡាយ កាលជំនាន់ព្រេងនាយ ដូចបានជម្រាបមកតាមលំដាប់នោះ គង់បានហៅខ្លួនឯងថាជាតិ កស្មីរឬកមីរ តែម្ដង! ឯពាក្យថា មុណ្ឌៈក្តី មនក្តី កើតជាខាងក្រោយទេ។ ឯពាក្យថា មន-ខ្មែរ ទើបតែអ្នកប្រាជ្ញអាឡឺម៉ង់ឈ្មោះ Wilhem Schmidt សន្មតហៅមុនគេបង្អស់ ប្រមាណជិត៧០ឆ្នាំប្លាយមកប៉ុណ្ណោះឯង។ ក្នុងពង្សាវតារយោនកៈឬក្នុងដំណាក់កាលនៃគម្ពីរចាម ទេវីវង្ស ហៅ មន ថា មេង បាលីថា មេគ្គបុត្ត (កូនជាតិមេង) ពាក្យថា មេង ស្រដៀងគ្នានឹងពាក្យចិនទាជីវ ដែលហៅខ្មែរយើងបច្ចុប្បន្ននេះថា ការ-មៀង ឬ ការមេង ភាសាវៀតណាមហៅខ្មែរថា កាវមៀង (Cao Mien)។ ពាក្យថា មេគ្គបុត្ត និងពាក្យថា មេង ដែលចិនហៅនោះស្រដៀងគ្នាណាស់។

ហេតុដែលពួកខ្មែរមួយក្រុមប៉ែកខាងលិចឱ្យទៅជា មន ហើយពួកខ្មែរខាងកើតឱ្យទៅជា ខម នេះ អាចជានយោបាយ ក្នុងជំនាន់ពុទ្ធសតវត្សរ៍ទី១៩ កន្លងមកហើយក៏សឹងបាន។

ដល់មកត្រង់នេះ ខ្ញុំសូមជម្រាបអស់លោកនិងប្អូនៗ ដើម្បីរំឭកថា “យើងកំពុងតែបណ្ដែតអារម្មណ៍ក្នុងការស្រាវជ្រាវរកឱ្យឃើញថាតើ ខមនិងខ្មែរ ជាជនជាតិតែមួយឬអ្វី? នៅត្រង់ផ្នែកកណ្ដាល យើងបានវែកញែកអំពីដើមកំណើតមនុស្សនៃយុគថ្មថ្មី ដែលហៅថា Neolithic Period គឺមានអាយុប្រមាណ ៣.៥០០.៥០០ឆ្នាំមុនគ្រិស្តសករាជ ហើយផ្នែកចុងខាងក្រោយបង្អស់ យើងបានមកដល់ចំណុចមួយដែលថា អម្បូរមន-ខ្មែរ ទាំងអស់ បានភៀសខ្លួនរត់ដោយភ័យសង្គ្រាមពីភូមិភាគប៉ែកខាងត្បូងភ្នំហិមាល័យ ត្រង់កន្លែងដែលហៅថា កស្មីរ សព្វថ្ងៃនេះ”។

តទៅនេះ សូមពិនិត្យតទៅទៀតៈ

## ដំណើរអម្បូរមន-ខ្មែរមកកាន់អាស៊ីអាគ្នេយ៍

អំពីដំណើរមន-ខ្មែរ រត់ពីដែនខាងត្បូងនៃភ្នំហិមាល័យ មកកាន់អាស៊ី

អាគ្នេយ៍ បើយើងពិចារណាតាមលំនាំបុរាណវិទ្យានិងប្រវត្តិសាស្ត្រ ឃើញថា មិនមែនមកម្តងមួយក្រុមនោះទេ គឺថា រត់ភៀសខ្លួនច្រើនលើក ច្រើនគ្រារាប់មិនអស់ ហើយច្រើនរយសតវត្សរ៍ផង គឺរាប់តាំងពីយុគថ្មចាស់ ដែលហៅថា Palae-olithic Period ចុះមក មុនយុគគម្ពីរព្រះវេទ រហូតដល់សម័យក្សត្រិយ៍កនិស្សកៈនៃរាជវង្សកុសាណៈ ក្នុងសតវត្សរ៍ទី៧–៨។

នៅប្រទេសឥណ្ឌា ត្រង់រដ្ឋបញ្ជាប់ ដែលនៅជិតកស្មីរនោះ គេបានរកឃើញគ្រឿងប្រើប្រាស់ ដែលហៅថា Pebble (ថ្មក្រួស) ក្នុងស្ទឹង Soan។ វប្បធម៌បែបនេះ ហៅថា Soan Culture មានលក្ខណៈដូច Pebble ដែលបានរកឃើញនៅប្រទេសម៉ាឡេស៊ីនិងលាវ។ រឿងនេះ ធ្លាប់បានជម្រាបមកហើយ ដូច្នេះទើបឃើញថា នៅយុគនោះ ពួកមនុស្សយុគ Palaeolithic មានរត់មកនៅអាស៊ីអាគ្នេយ៍ទៅហើយ។ នៅយុគ Mesolithic ក៏មានរកឃើញគ្រឿងប្រើប្រាស់ជាពូថៅ ថ្មរំលីង ដែលជាស្នាដៃកាន់តែល្អឡើង (Handaxe) ទាំងលើផ្ទៃដីឥណ្ឌា ថៃ លាវ យួន រហូតដល់ឥណ្ឌូណេស៊ី។ លុះដល់យុគថ្មថ្មី គេក៏បានរកឃើញគ្រឿងប្រើប្រាស់ ដែលហៅថា Shouldered celt លើផ្ទៃដីឥណ្ឌាប៉ែកខាងជើងផុតនិងទៅលើផ្ទៃដីអាស៊ីអាគ្នេយ៍។ ដូច្នេះ ក៏ឃើញថានៅយុគថ្មថ្មីឬ Neolithic Period នេះ មានមនុស្សពីឥណ្ឌាមកនៅអាស៊ីអាគ្នេយ៍ កាន់តែច្រើនឡើងហើយ។

ការភៀសខ្លួននៃអម្បូរខ្មែរសម័យនោះដែលបែកមកខាងត្បូង គង់នៅសភាពមិនចម្រើននៅឡើយ ប៉ុន្តែ បើយើងសិក្សាអំពីវប្បធម៌ "បានចៀង" ដែលនៅត្រង់អាណាចក្រគោត្របូរពីដើម ក៏ឃើញថា យុគលោហៈនៃអាស៊ីភាគកណ្តាលត្រង់នេះ បានឡើងកាន់ឋានៈជាអារ្យជនមុនភាគឯទៀតនៃអាស៊ីអាគ្នេយ៍ ព្រោះគេបានជីករកឃើញវប្បធម៌ដីដុតនិងដីប៉ាន់លាបពណ៌មានអាយុ ៧.០៦៩–៦.០៧៩មកហើយ ឃើញថានៅម្តុំត្រង់នេះអាចមានអម្បូរមន-ខ្មែរ មកនៅយូរយារណាស់ គឺអាចបានមកពីទិសខាងជើងភ្នំហិមាល័យ មុនជំនាន់ជាតិអរិយកៈ

មកដេញអម្បូរខ្មែរ-មន ឱ្យចេញពីអាណាបរិវេណទន្លេសិន្ធុ។

ការភៀសខ្លួនរត់ទៅកាន់អាស៊ីប៉ែកអាគ្នេយ៍ មានបន្តមកច្រើនគ្រា នៅសម័យដែលប្រទេសឥណ្ឌាមានប្រវត្តិសាស្ត្រពិតប្រាកដហើយ។ ការរត់ភៀសខ្លួននៅសម័យនេះ បើពិចារណាតាមលក្ខឋានផ្នែកពុទ្ធសាសនា មានគម្ពីរមហាវង្សនិងមិលិន្ទបញ្ហាជាដើមនេះមួយ, មួយទៀត បើពិចារណាតាមព័ស្តុតាងជាឯកសាររបស់រាជទូតចិន អ្នកជំនួញជាតិក្រិកនិងអារ៉ាប់ ក៏គួរឱ្យឃើញថា ការភៀសខ្លួននៅសម័យប្រវត្តសាស្ត្រនេះ មានមូលដ្ឋាន៣ប្រការគឺៈ

១–មកពីការរកស៊ីចិញ្ចឹមជីវិត,

២–មកពីសង្គ្រាម,

៣–មកពីរឿងសាសនា។

តទៅនេះ ខ្ញុំសូមទាញរឿងរ៉ាវដែលមាននៅក្នុងប្រវត្តិសាស្ត្រឥណ្ឌាខ្លះមកពិចារណា ដូចតទៅៈ

តាមព័ស្តុតាងដែលបានស្រាវជ្រាវក្នុងគម្ពីរព្រះវេទ គេបានឱ្យដឹងថា ជនជាតិអរិយកៈ បានផ្សាយឥទ្ធិពលលើដែនដីតាមដងទន្លេសិន្ធុ តាមដងទន្លេគង្គា ហើយបានតាំងអាណាចក្រយ៉ាងសំខាន់ៗច្រើនកន្លែង ដែលសំខាន់ជាងគេគឺអាណាចក្រមគធរដ្ឋ។ អាណាចក្រនេះ ជាមជ្ឈមណ្ឌលសំខាន់នៃឥទ្ធិពលជនជាតិអរិយកៈ មានអំណាចផ្សាយទាំងផ្លូវពុទ្ធចក្រនិងអាណាចក្រក្នុងសម័យពុទ្ធកាល។

តមក សម័យដើមពុទ្ធកាល ប្រទេសអៀរ៉ង់ (Iran) ក្នុងសម័យរាជវង្សអាចាមេនីដ (Achaemenid) ក៏បានផ្សាយចូលគ្រប់គ្រងឥណ្ឌាប៉ែកខាងទន្លេសិន្ធុដែរ ជាហេតុនាំឱ្យមានអ្នកភៀសខ្លួនរត់គេចចេញពីកន្លែងនេះទៅទៀត។

ក្នុយរយៈសតវត្សរ៍ទី៦ មុនគ្រិស្តសករាជ អាណាចក្រគន្ធារៈ (Gandhāra) ដែលនៅប៉ែកខាងលើទន្លេសិន្ធុ មានស្រុកឈ្មោះថា ប៉េសវ៉ារ (Peshawar) និងរ៉ាវ៉ាល់ពិនឌី (Rawalpindi) បានឱ្យរាជទូតនាំសារចូលមកថ្វាយព្រះចៅពិម្ពិសារនៃ

មគធរដ្ឋ ក្នុងសំបុត្រនោះមិនប្រាកដថាជាអ្វី ប៉ុន្តែដែលដឹងទូទៅគឺ ដែនគន្ធាររដ្ឋ បានត្រូវស្តេចវង្សអាចាមេនាន (Achaemenian) មកវាយ។ អាណាចក្របរិវេណ ឆ្នេរទន្លេសិន្ធុ បានធ្លាក់ទៅក្នុងកណ្តាប់ដៃអៀរ៉ង់ (Iran) តាំងតែពី ៥២២-៤៨៦ ឆ្នាំមុនគ.ស. ម្ល៉េះ។

តមក ៣២៧ ឆ្នាំមុនគ.ស. ព្រះចៅអាឡិចក្សង់ដារ (Alexander) មហារាជនៃម៉ាសេដូនា (Macedonia) បានចូលមកពីហិណ្ឌូគូជ ហើយបានវាយយកអាណាខេត្តតាមដងទន្លេសិន្ធុ ដែលពួកអៀរ៉ង់គ្រប់គ្រងនោះទៅវិញហើយបានលើកទ័ពឆ្លងទន្លេសិន្ធុឆ្ពោះទៅកាន់ទន្លេគង្គា តែពួកសេនាទាហានបានឃាត់ទើបត្រឡប់ទៅវិញ។ ពេលនោះ អម្បូរមន-ខ្មែរ ដែលនៅទីនោះ ក៏បាននាំគ្នារត់គៀសខ្លួនពីភ័យសង្គ្រាមម្តងទៀត។

ព្រះចៅចន្ទ្រគុប្ត ( ៣២១-២៩២ មុនគ.ស.) នៃរាជវង្សមោរិយៈក្រោយដែលអាឡិក្សង់ដារ (Alexander) មហារាជទ្រង់សោយទិវង្គតហើយ ឥទ្ធិពលក្រិកនៅខាងលិចឆៀងខាងជើងនៃប្រទេសឥណ្ឌា ក៏អស់ទៅដែរ។ ក្នុងឆ្នាំ ៣២១ មុនគ.ស.ព្រះចៅចន្ទ្រគុប្ត បានប្រាបប្រាមដែនដីនានាប៉ែកខាងជើងនៃឥណ្ឌាបានចាត់តាំងអាណាចក្រធំ មានទីក្រុងឈ្មោះបាតលីបុត្រ។ ពេលនេះ អម្បូរមន-ខ្មែរ ក៏គង់រត់គេចពីរាជភ័យម្តងទៀត។ តពីសម័យព្រះចៅចន្ទ្រគុប្តមក ព្រះរាជបុត្រទ្រង់ព្រះនាម ពិន្ទុសារ ក៏ទ្រង់សោយរាជ្យត ព្រះអង្គទ្រង់មានព្រះរាជសម្ព័ន្ធមេត្រីនឹងអាណាចក្រ ប៉ឺសៀ អាណាចក្រនេះ ក៏សុខស្ងប់រហូតមក។

ប្រមាណ៣០០ឆ្នាំមុនគ.ស. ព្រះពុទ្ធសាសនាចម្រើនរុងរឿងណាស់នៅប្រទេសឥណ្ឌា ព្រោះមានស្តេចសំខាន់ៗ ដូចជាព្រះចៅអសោកមហារាជនៃមោរិយវង្ស ជួយឧបត្ថម្ភទំនុកបម្រុង។

ព្រះចៅអសោក (២៧៤-២៣៧ឆ្នាំមុនគ.ស.) ព្រះចៅអសោកជាព្រះរាជបុត្រព្រះចៅពិន្ទុសារ បានត្រូវគេលើកថាជាក្សត្រិយ៍ខ្លាំងពូកែមួយព្រះអង្គ ដែល

មិនងាយរកបានក្នុងលោកនេះ។ ក្នុងរជ្ជសម័យព្រះបាទអសោកនេះ មានធ្វើសឹកសង្គ្រាមជាញឹកញាប់ ដើម្បីផ្សាយរាជអាណាចក្រឱ្យបានរីកធំទូលាយឡើងទៀត ព្រះអង្គវាយបានដែនដីហៅថា អាហ្វាហ្គានិស្ថាន បាលូចិស្ថាន កស្មីរ នេប៉ាល់ សិក្ខិម ហើយនឹងដែនដីភាគខាងជើងនៃប្រទេសឥណ្ឌាទាំងអស់ គឺរាប់ចាប់តាំងពីដងទន្លេសិន្ធូទៅ រហូតដល់ឈូងបេងកាល ប៉ែកខាងលិចរហូតទៅដល់ទន្លេកប្ញស្នា។

ក្នុងឆ្នាំ២៦២មុនគ.ស. ព្រះអង្គបានលើកទ័ពទៅប្រាបប្រាមពួកក្លិង្គក្នុងរដ្ឋអូរីស្សាដែលនៅវាងស្ទឹងមហានទីនិងគោទាវរី។ ពួកក្លិង្គបានតស៊ូយ៉ាងម៉ឺងម៉ាត់ ប៉ុន្តែត្រូវចាញ់នៅទីបំផុត។ ការប្រយុទ្ធគ្នាពេលនោះជាហេតុធ្វើឱ្យស្លាប់បាត់បង់ជីវិតនៃទាហានទាំងពីរផ្នែកអស់ច្រើនណាស់។ តាំពីនោះមក ព្រះបាទអសោកទ្រង់មានព្រះទ័យតក់ស្លុតណាស់ ទើបទ្រង់ព្រះតម្រិះយកព្រះពុទ្ធសាសនាជាទីពឹងប្រកាសឈប់ធ្វើសឹកសង្គ្រាមដោយកម្លាំងតាំងពីពេលនោះមក ទ្រង់យកព្រះធម៌ជាធំ ទ្រង់ប្រកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន ទ្រង់ផ្សាយបរមរាជានុភាពដោយធម្មានុភាពទៅវិញ។

ក្រោយរជ្ជសម័យព្រះបាទអសោក ប្រទេសឥណ្ឌាបានថយកិត្យានុភាពក្សត្រិយ៍អង្គតៗមក គ្មានបានសាងថ្មីដែអ្វីឡើយ មោរិយវង្សក៏អស់អំណាចក្នុងឆ្នាំ១៨៤ មុនគ.ស.ឬប្រមាណព.ស.៣៥៦។

ក្នុងជំនាន់ព្រះបាទអសោកមហារាជនេះ មានជនជាតិឥណ្ឌាទាំងអម្បូរមនខ្មែរនិងពួកឥណ្ឌាដែលហៅថាអរិយកៈ បានភៀសខ្លួនចេញពីប្រទេសឥណ្ឌាច្រើនណាស់។ ការចេញពីប្រទេសឥណ្ឌា ទៅនៅទីផ្សេងៗក្រៅប្រទេស គួរឱ្យសន្និដ្ឋានថា មកពីហេតុ៤ប្រការគឺៈ

១–មកពីព្រះរាជបំណងរបស់ព្រះបាទអសោក ដែលទ្រង់មានអ្នកប្រាជ្ញរាជបណ្ឌិត្យទាំងគ្រហស្ថ ទាំងបព្វជិត ជួយផ្សព្វផ្សាយព្រះពុទ្ធសាសនា ម្ល៉ោះ

ហើយជនជាតិឥណ្ឌាសម័យនោះ ក៏បានចេញទៅកាន់ដែនដីនានាក្រៅប្រទេស ដោយអំណាចរាជានុភាព សុវណ្ណភូមិឬអាស៊ីអាគ្នេយ៍ ជាដែនដីមួយដែលពួកឥណ្ឌាទាំងអម្បូរមន-ខ្មែរនិងអរិយកៈបានចូលមកនៅ សម័យនេះផ្ទៃដីអាស៊ីអាគ្នេយ៍នៅមិនទាន់គោកសព្វគ្រប់ដូចសព្វថ្ងៃទេ តែនៅលើទីនានានៃផ្ទៃដីគោក ក៏គង់មានអម្បូរមន-ខ្មែរ មកនៅពេញអស់ទៅហើយ។ គួរឱ្យជឿជាក់ថា ពួកនាគឬពួកជនជាតិនាគ ក៏ជាអម្បូរខ្មែរមួយក្រុម អាចមកនៅទីនេះមុនគេបង្អស់។ ហេតុដែលជឿជាក់ថា នាគជាបុព្វបុរសខ្មែរមួយក្រុមនោះ ពីព្រោះរឿងរ៉ាវនាគនេះ មានទាក់ទងនឹងប្រវត្តិសាស្ត្រយើងជាច្រើនអន្លើ។ យើងជាអនុជន គួរគប្បីសិក្សាស្រាវជ្រាវរឿងនេះឱ្យពិតប្រាកដ យើងកំពុងប្រមូលចិត្តយើងក្នុងជំនឿថា "នាគជាសត្វ" តែគួរឱ្យជឿថា មនុស្សឬអម្បូរមនុស្សដែលទាក់ទងជាកុលសម្ព័ន្ធនឹងយើងទៅវិញ។ សព្វថ្ងៃពូជមនុស្សនាគនេះ មាននៅក្នុងផ្ទៃដីជ្រោយម៉ាឡាយូនិងព្រំដែនឥណ្ឌា ភូមា។

២–ពួកក្រៅសាសនា បានដល់ជនជាតិអរិយកៈនិងអម្បូរមន-ខ្មែរដែលធ្លាប់កាន់ព្រហ្មញ្ញសាសនារួចមកហើយ តែលុះព្រះបាទអសោកបែរមកទំនុកបម្រុងព្រះពុទ្ធសាសនាវិញនោះ ក៏ជាហេតុនាំឱ្យពួកសាសនាព្រាហ្មណ៍មិនពេញចិត្តទើបរត់ភៀសខ្លួន ព្រមទាំងនាំសាសនាព្រាហ្មណ៍ចូលមកអាស៊ីអាគ្នេយ៍ ដើម្បីបន្តជំនឿរបស់ខ្លួនលើទីនេះតទៅ ដោយពុំចង់ឱ្យមានអ្នកណាមកបៀតបៀនបានទៀតឡើយ។

៣–រត់ភ័យគេចពីសង្គ្រាម ដែលពេលនោះប្រទេសឥណ្ឌារំជួយដោយសេនានុភាពនៃកងទ័ពព្រះបាទអសោក ពួកដែលភៀសខ្លួនមកនៅអាស៊ីអាគ្នេយ៍ពេលនោះ មានជនជាតិគ្រប់ជាន់ គ្រប់អម្បូរ គ្រប់ភាគីពីប្រទេសឥណ្ឌា ប៉ុន្តែអាចមានពួកវណ្ណៈជាន់ខ្ពស់ ដូចជាវណ្ណៈក្សត្រិយ៍ ហើយនិងព្រាហ្មណ៍ដែលមិនព្រមនៅក្រោមអំណាចព្រះចៅអសោកនោះ ក៏បាននាំគ្នាមករកកន្លែងថ្មីនៅ

អាស៊ីអាគ្នេយ៍ដែរ ដើម្បីតាំងជារដ្ឋធានីថ្មីដោយឡែក។ ក្នុងដំណាលបុរាណ មានដំណាលសុវណ្ណខូមខាំជាដើម ក៏បាននិយាយអំពីព្រះវង្សស្តេចដែលមកពីប្រទេសឥណ្ឌានោះ ហើយដែលបានមកធ្វើធំនៅអាស៊ីអាគ្នេយ៍នោះដែរ។

៤–ពួកអ្នកជួញព្រេង បានដល់ជនដែលចង់រកស៊ីមានបាន ព្រោះឮដំណឹងថា ផ្ទៃដីភូមិភាគអាស៊ីអាគ្នេយ៍នោះដែរ សម្បូរសប្បាយរកស៊ីស្រួលងាយណាស់ បានជានាំគ្នាហូរចូលមក។ រឿងមកលក់ដូរធ្វើចម្ការដូច្នេះ គង់មានមកតាំងពីមុនសម័យព្រះចៅអសោកមហារាជក៏សឹងបាន បញ្ហានេះសូមឱ្យមើលក្នុងជាតកនានាផ្នែកពុទ្ធសាសនា មានមហាជនកជាតក សង្ខព្រាហ្មណ៍ជាតក និងសុសន្ទីជាតកជាដើម ក៏នឹងឃើញសេចក្តីច្បាស់។

ប្រវត្តិសាស្ត្រនៃប្រទេសឥណ្ឌា តាំងពីព.ស.៥៥០ ចុះមកដល់ព.ស. ១០៥០ ឃើញថាជាសម័យច្របូកច្របល់ណាស់ ខ្ញុំសូមលើកមកជូន ដើម្បីជាប្រយោជន៍ក្នុងការស្រាវជ្រាវអំពីអម្បូរមន-ខ្មែរ ព្រោះប្រទេសនេះ មានការទាក់ទងនឹងផ្ទៃដើមនៃប្រវត្តិសាស្ត្រជាតិយើងជាច្រើន។

នៅរយៈក្រោយព្រះចៅអសោកមក មានស្តេចច្រើនអង្គដែរ ប៉ុន្តែអំណាចដែលធ្លាប់មានកាលពីជំនាន់ព្រះចៅអសោកនោះ ដល់មកជំនាន់នេះ ក៏ខ្សោយអំណាចអស់។ មជ្ឈដ្ឋានអំណាចនៃប្រទេសឥណ្ឌា បានមកប្រាកដនៅពីរកន្លែងគឺៈ

–កន្លែងទី១ នៅភាគខាងពាយព្យប្រទេស ផ្ទៃដីត្រង់នេះធ្លាក់ទៅក្នុងកណ្តាប់ដៃក្រិក តែតមកបាននៅក្នុងអំណាចជនជាតិសីធៀន (Scythian)។

–កន្លែងទី២ នៅក្នុងភាគកណ្តាលនៃជ្រោយដេកខាន អាណាចក្រដែលរាជវង្សអាន្ធរៈបានចាត់តាំងឡើង ទុកណានៅរយៈនេះ ឥទ្ធិពលជាតិបរទេសអាចចូលមកឥណ្ឌាពីខាង (និរតី) ក៏ដោយ ក៏ប៉ុន្តែ វប្បធម៌និងប្រពៃណីបែបទមិឡទៅវិញ ហើយបាននៅក្រោមការគ្រប់គ្រងរាជវង្សអាន្ធរៈ ដែលជារាជវង្សរបស់ឥណ្ឌាដើមសុទ្ធ។ តមក រាជវង្សនេះបានពង្រីកអំណាចកាន់តែធំឡើងទៅលើភូមិ

ភាគដទៃនៃប្រទេស គឺពីជ្រោយដេកខាន ឡើងទៅដល់រដ្ឋមល្វៈ( Malwa) និងរដ្ឋមហារាស្ត្រ ( Maharashtra) ទាល់តែដល់ឈូងកាំបេយ៍ ( Cambay ) មុខស្រុកបុមបេយ៍ (Mombay) ទិសខាងលិច។ រីឯដែនដីភូមិភាគខាងលិចឆៀងខាងជើង បានផ្ទេរពីដៃក្រិកទៅឱ្យជនជាតិដែលបុករុកមកថ្មីទៀតគឺ ជនជាតិសកៈ ( Saka)។

ជនជាតិ Saka នេះជាពូជជនជាតិសីធៀង ( Scythian) ដែលកាលពីមុនធ្លាប់នៅលើផ្ទៃដីភាគខាងកើតនៃប្រទេសអៀរ៉ង់ (Iran )។ តមក ត្រូវបានជនជាតិនេចរ គឺយុយ-ចិ (Youh-chih) បណ្តេញឱ្យចូលមកនៅប្រទេសឥណ្ឌា រួមជនជាតិយុយ-ចិ ខ្លួនឯងក៏ត្រូវបានពួកហ្យុង-នូ (Hiong-nu) ឬហាន់ (Hun) បណ្តេញឱ្យចេញពីដែនដីមុងកុលមួយតំណទៅទៀត ហេតុការណ៍នេះបានឧប្បត្តិឡើងរវាង ព.ស.៤២៥–៤៥០។ ដោយអាស្រ័យហេតុនេះឯង ទើបពួកជនជាតិយុយ-ចិបែកបាក់គ្នា បានមកប្រាកដខ្លួននៅពាសពេញលើអាណាបរិវេណដែលធ្លាក់នៅក្រោមឥទ្ធិពលរបស់ជាតិក្រិកនិងអៀរ៉ង់កាលពីមុន។ តមក ពួកយុយ-ចិនេះមានឥទ្ធិពលកាន់តែខ្លាំងឡើងៗ ទើបបានចូលវាយយកដែលដីដែលហៅថា Bactria និង Seistan ឱ្យនៅក្រោមអាណាព្យាបាលរបស់ខ្លួន។ ដែនដីទាំងពីរនេះនៅខាងត្បូងប្រទេសអាហ្វហ្គានិស្ថាន រួមទាំងរដ្ឋគន្ធារៈផង រដ្ឋនេះគឺដែនដីដែលហៅថា ប៉េស្វារ (Peshawar) បច្ចុប្បន្ននេះឯង។ តមក ក្នុងពុទ្ធសតវត្សរ៍ទី៦-៧ រដ្ឋនានា ដូចជាបញ្ចាបខាងលិច គឺក្រុងតក្កសិលា រដ្ឋកាបិសៈ (Kapisa) គឺអាណាបរិវេណបេគ្រាម (Begram) ក្នុងប្រទេសអាហ្វហ្គានិស្ថាន រដ្ឋបញ្ចាបខាងលិចនិងរដ្ឋសិន្ទុ ក៏ធ្លាក់ទៅនៅក្នុងកណ្តាប់ដៃរាជវង្សកុសាណៈ (Kusāna) ដែលជាពូជជនជាតិយុយ-ចិដដែលនេះ។

រាជវង្សកុសាណៈនេះ បានតាំងអាណាចក្រយ៉ាងធំ មានអំណាចតាំងតែពីដងទន្លេអកស៊ស (Oxus) ដែលជាដែនដីនៅប៉ែកខាងពាយព្យនៃប្រទេសឥណ្ឌា រហូតដល់អាណាបរិវេណទន្លេគង្គា មានក្រុង Bactaria (បាក់តេរៀ) និងកាប៊ុល

(Kabul) ជាមជ្ឈមណ្ឌលទ្រទ្រង់ឥទ្ធិពលនៃរាជវង្សកុសាណៈនេះ។ អំណាចរាជវង្សនេះ បានផ្សាយទៅដល់រដ្ឋសកឌីយ៉ាណា (Sogdiana) ហើយនឹងភាគកណ្តាលនៃទ្វីអាស៊ី ហើយផ្សាយមកជ្រោយឥណ្ឌូចិនផង ព្រោះនៅទីនេះគេបានរកឃើញសិល្បៈបែបអៀរ៉ង់ (Iran) លាយឡំជាមួយខ្លះ។ ក្សត្រិយ៍រាជវង្សកុសាណៈ ដែលមានព្រះនាមល្បីជាងគេ គឺព្រះចៅកនិស្កៈ (Kaniska) ដែលជាពុទ្ធសាសនិក ហើយអាចជាអ្នកតាំងមហាសករាជឡើងក្នុងព.ស.៦២១ក៏សឹងបាន ព្រោះឆ្នាំនោះ គឺជាឆ្នាំដែលឡើងសោយរាជ្យ។

ចក្រវត្តិនេះ មានអំណាចរុងរឿងប្រមាណ១០០ឆ្នាំ តពីនោះ អំណាចបានត្រូវថយចុះ ព្រោះមហាក្សត្រប្រទេសឥណ្ឌាបានត្រូវបែងជារដ្ឋតូចធំជាច្រើន ដែលមានរាជវង្សស្រកៈឡើងកាន់អំណាចជំទាស់។ អាណាបរិវេណក្បែរក្រុងបុមបេយ៍ ក៏បានត្រូវបែងចែក ហើយនៅពេលជាមួយគ្នានោះ អាណាបរិវេណប៉ែកខាងត្បូងនៅក្រោមឥទ្ធិពលរាជវង្សអាន្ទារៈ ក៏ត្រូវបានបែងចែកជា២ភាគ ក្នុងពុទ្ធសតវត្សរ៍ទី៨។ តមក រាជវង្សសំខាន់របស់ឥណ្ឌាមួយទៀត គឺរាជវង្សគុប្តៈ (Gupta) បានរួបរួមប្រទេសឥណ្ឌាជាថ្មីម្តងទៀត។

ក្នុងយុគនេះ ប្រទេសឥណ្ឌាបានចម្រើនលូតលាស់ក្នុងវិស័យសេដ្ឋកិច្ច ជាទីបំផុត មានការទាក់ទងតាមផ្លូវពាណិជ្ជជាមួយប្រទេសនានា ដែលនៅខាងលិចនៃទ្វីបអាស៊ី ហើយនឹងដែនដីមុំទន្លេមេឌីធើរេនាន (Mediteranian) ក្នុងទ្វីបអឺរ៉ុប។ ក្រៅពីនេះមានការទាក់ទងនឹងប្រទេសនៅប៉ែកទន្លេភាគខាងត្បូងនៃទ្វីបអាស៊ីផងដែរ។ ការទាក់ទងដូច្នេះ យើងដឹងមកពីការជីករកឃើញព័ស្តុតាងតាមអាណាបរិវេណទូទៅបានយ៉ាងច្រើនលើសលប់។ ព័ស្តុតាងដែលបានរកឃើញនៅក្រុងតក្កសិលា ជាហេតុឱ្យឃើញច្បាស់អំពីការទាក់ទងរវាងប្រទេសឥណ្ឌានិងប្រទេសមេសូប៉ូតានី ក្នុងរយៈ១០០ឆ្នាំមុនពុទ្ធសករាជ រហូតដល់សម័យពុទ្ធកាល។ ការទាក់ទងរវាងប្រទេសឥណ្ឌានឹងអៀរ៉ង់ (Iran) បានមានឡើងតាំងពីពុទ្ធសតវត្សរ៍ទី

១ ហើយនឹងការទាក់ទងរវាងប្រទេសក្រិក បានមានឡើងប្រមាណពុទ្ធសតវត្សរ៍ទី ២។ វត្ថុព័ស្តុតាងដែលបានរកឃើញតៗមក បានជាសាក្សីឱ្យឃើញច្បាស់នូវការទាក់ទងយ៉ាងទូលំទូលាយផ្នែកពាណិជ្ជកម្មក្នុងសម័យនោះ។ ក្រៅពីប្រាក់រៀលរោមន៍ ដែលបានរកឃើញដោយទូទៅក្នុងផ្ទៃប្រទេសឥណ្ឌា ហើយគេបានជីកឃើញវត្ថុគ្រឿងប្រើប្រាស់ ធ្វើដោយដៃពីកំបោរដែលជារបស់ក្រិក-រោមន៍ឬវត្ថុដែលបានមកពីក្រុងអាឡិកសានដ្រា (Alexandria) ប្រទេសអ៊ីហ្ស៊ីប។ គ្រឿងសំ-ឫទ្ធិក្រក-រោមន៍និងគ្រឿងកែវទាំងអស់នេះ គេបានរកឃើញនៅស្រុកកាពិស៊ី (Kapisi) ឬស្រុកបេគ្រាម ដែលជាក្រុងចាស់នៃរដ្ឋកាមិសៈ។ ស្រុកនេះសព្វថ្ងៃតាំងនៅក្នុងប្រទេសអាហ្វហ្គានិស្ថាន ដែលគេបានរកឃើញគ្រឿងប្រើប្រាស់ដែលធ្វើពីខ្នុកជារបស់ចិន។ ក្រៅពីនេះ នៅមានអំបែងដីដុតនិងក្បាលចិញ្ចៀនរោមន៍ជំនាន់ព្រះចៅអ័គសត័ស (Augustus) ហើយនឹងព្រះចៅក្លូឌិស (Claudis) ក្នុងពុទ្ធសតវត្សរ៍ទី៦។ របស់អស់នេះ បានរកឃើញនៅភាគខាងត្បូងនៃដែនដីប្រទេសឥណ្ឌា ត្រង់ស្រុកដែលមានឈ្មោះថា អរិកៈមេឌុ (Arikamedu) ហើយនឹងស្រុកវីរប័តណាំ (Virapatnam) ជិតស្រុកប៉នទិឆេរី (Pondichery) ក្រៅពីនេះ នៅកូសាំងស៊ីន (Cochinchina) ក្នុងប្រទេសវៀតណាមខាងត្បូង (កម្ពុជាក្រោម) ត្រង់កំពង់ផែខ្មែរបុរាណ ដែលមានឈ្មោះថា អូរកែវ (Oc-Eo) នោះ គេបានរកឃើញក្បាលចិញ្ចៀនប្រាក់រៀលនិងគ្រឿងប្រើប្រាស់រោមន៍ សម័យចក្រពត្តិរោមន៍៧អង្គ ក្នុងរវាងព.ស.៦៣៤–៧៣៥ ហើយនឹងសិល្បៈបែបអៀរ៉ង់ (Iran) ជំនាន់រាជវង្សសស្សានិតទៀតផង។

ហេតុនេះ ទើបឃើញថាក្នុងយុគនេះ ប្រទេសឥណ្ឌាមានការទាក់ទងយ៉ាងទូលំទូលាយរវាងប្រទេសក្រិក អៀរ៉ង់និងប្រទេសនានានៅអាស៊ីអាគ្នេយ៍។

ខ្ញុំសូមសរុបសេចក្តីនៃការប្រែប្រួល បែកញែកយ៉ាងច្របូកច្របល់នៃប្រទេសឥណ្ឌានេះឱ្យខ្លីម្តងទៀត ដើម្បីងាយស្រួលក្នុងការស្រាវជ្រាវ។

ដែនដីឥណ្ឌាប៉ែកខាងលិចឆៀងខាងជើងបន្តិច គឺត្រង់ដែលហៅថា បុមបេយ៍ រដ្ឋមហារាស្រ្ត រដ្ឋមល្វៈជាដើម បានធ្លាក់ទៅក្នុងកណ្តាប់ដៃជនបរទេស គឺជាតិសីធៀន (Scythian) ក្នុងពុទ្ធសតវត្សរ៍ទី៥-៦។ គួរឱ្យសង្កេតថា រដ្ឋកម្ពោជៈដែលជាដែនដីជាតិអម្បូរមន-ខ្មែរ បានទៅតាំងនៅក្រោយពីការរត់ភៀសខ្លួនពីរដ្ឋកស្មីរនោះ ក៏បាននៅក្រោមអំណាចជាតិបរទេសដែរ ព្រោះស្រុកនោះនៅខាងត្បូងគន្ធាររដ្ឋ នៅឆ្នេរសមុទ្រខាងជើងក្រុងបុមបេយ៍ សព្វថ្ងៃហៅថា គុជរដ្ឋ។ កាលពីជំនាន់ដើម គុជរដ្ឋនេះ មានឈ្មោះថារដ្ឋវលភីឬអាណាចក្រវលភី។ រីឯស្រុកកម្ពោជៈនោះ ព្រះអង្គបានតាំងក្រុមមួយឈ្មោះថា ទ្វារកៈ ដល់មកជំនាន់សីធៀនមកគ្រប់គ្រង អម្បូរមន-ខ្មែរ អាចមិនពេញចិត្ត ទើបរត់ភៀសខ្លួនចេញមកប៉ុន្តែបន្តិចបន្តួចទេ។ តមក ភាគខាងលិចនេះបានផ្ទេរអំណាចទៅឱ្យរាជវង្សអន្ធារៈដែលមកពីដេកខានទិសខាងត្បូងទៅវិញ ក៏អាចជាហេតុឱ្យអម្បូរមន-ខ្មែរ ដែលនៅត្រង់នេះមានការភិតភ័យម្តងទៀត ប៉ុន្តែអាចមិនជាប៉ុន្មានដែរទេ។

ភូមិភាគខាងពាយព្យ ត្រង់ដងស្ទឹងសិន្ធូ កស្មីរ បញ្ចាបជាដើម ដែលជាកន្លែងអម្បូរមន-ខ្មែរនៅពីជំនាន់ដើមនោះ បានផ្ទេរអំណាចពីកណ្តាប់ដៃក្រិកដែលបានបន្តពូជពីអាឡិកក្សិនដារ (Alexander) នោះ ឱ្យមកនៅក្រោមអំណាចជាតិបរទេសថ្មី ដែលមានឈ្មោះថា សកៈ ទៅវិញ ដែលមានពូជមកពីជាតិសីធៀន។ ពួកនេះ កាលពីដើមនៅត្រង់តំបន់ខាងកើតនៃប្រទេសអៀរ៉ង់ តែតមកត្រូវពួកយុយ-ចិបណ្តេញចេញមក បានមកមានឥទ្ធិពលលើដែនដីអម្បូរមន-ខ្មែរ ប៉ែកខាងជើងនោះឯង។ រីឯពួកយុយ-ចិនេះ ពីដំបូងបានត្រូវពួកហ៊ុន (Hun) បណ្តេញចេញពីដែនដីម៉ុងហ្គោល ហើយបានមកជ្រែកនៅពាសពេញលើផ្ទៃដីប្រទេសឥណ្ឌា។ តមកពួកនេះមានមហិទ្ធានុភាពកាន់តែខ្លាំងឡើងៗ ទាល់តែមានអំណាចគ្របសង្កត់លើដែនដីនានាដែលនៅជិតខាងគឺរដ្ឋបាក់ទ្រា (Bactria) និងសេស្ថាន (Seistan) ដែលសព្វថ្ងៃនៅក្នុងដែនដីប្រទេសអាហ្វហ្គានិស្ថាន

(Afghanistan)។ រដ្ឋគន្ធារៈ, ប៉េសវ៉ារ (Peshawar) ក៏បាននៅក្រោមឥទ្ធិពលពួកយុយ-ចិដែរ។ តមក ដែនដីដងទន្លេសិន្ធុ គឺក្រុងតក្កសិលា (ដែលធ្លាប់ជាក្រុងនៃអម្បូរមន-ខ្មែរ ប៉ែកខាងត្បូងភ្នំហិមាល័យខាងត្បូងពីដើម) រដ្ឋកាបិសៈ (Kapisa) រដ្ឋបញ្ចាប, រដ្ឋទាំងអស់នេះ បានធ្លាក់នៅក្រោមកណ្ដាប់ដៃរាជវង្សយុយ-ចិ ដែលមានឈ្មោះថា កុសាណៈ (Kusāna) ក្នុងពុទ្ធសតវត្សរ៍ទី៦-៧។

ឥទ្ធិពលនៃរាជវង្សកុសាណៈនេះ មានទូលំទូលាយផ្សាយទៅឆ្ងាយណាស់ រហូតដល់មកជ្រោយឥណ្ឌូចិនយើងនេះ, តែនៅអូរកែវ (Oc-Eo) ដែលជាកំពង់ដៃខ្មែរបុរាណនេះ បើពិចារណាលើវត្ថុដែលគេបានជីកឃើញ ដូចក្បាលចិញ្ចៀន និងវត្ថុគ្រឿងប្រើប្រាស់ឯទៀតៗជាដើម គួរឱ្យឃើញថាមានការទាក់ទងរវាងដែនដីត្រង់នេះនិងជាតិអៀរ៉ង់ហើយនឹងជាតិរោមន៍ផង រួចគួរឱ្យជឿថា ការទាក់ទងនេះ គង់មានតាំងពីសម័យដើមពុទ្ធកាល រហូតដល់ពុទ្ធសតវត្សរ៍ទី៨មុននេះ។

តទៅនេះ ខ្ញុំសូមវិនិច្ឆ័យតាមទស្សនៈផ្ទាល់ខ្លួនសុទ្ធសាធ ដែលខ្ញុំពុំបានចាត់ទុកថា ជាការវិនិច្ឆ័យផ្ដាច់ព្រាត់ដោយឱ្យអស់តែត្រឹមនេះទេ គឺថា អាចមានតុលាការជាន់ខ្ពស់ដែលមានទស្សនៈ មានព័ស្តុតាងល្អជាងខ្ញុំរកឃើញនៅថ្ងៃក្រោយទៀត។ ពួកតុលាការជាន់ខ្ពស់នោះ បានដល់ព្រះតេជព្រះគុណ អស់លោកនិងប្អូនៗបញ្ញវន្តជំនាន់ក្រោយនោះឯង ដែលបានស្រាវជ្រាវ ហើយបានវិនិច្ឆ័យដោយមានព័ស្តុតាងល្អជាង ប្រសើរជាងខ្ញុំក៏បានដែរ គ្រាន់តែធ្វើដូចម្ដេចឱ្យអស់លោកនិងប្អូនៗ បានបញ្ចេញនូវគំនិតដែលប្រកបដោយជម្រៅនៃអ្នកប្រាជ្ញក្នុងការស្វះស្វែងរកលក្ខឋានអម្បូរជាតិយើង ឱ្យបានពិតប្រាកដឡើង ដើម្បីជាប្រយោជន៍ក្នុងការបន្តពូជពង្សរបស់ខ្លួន ឱ្យបានស្ថិតស្ថេរចីរកាលតរៀងទៅក្នុងឆាកអន្តរជាតិ ហើយជាកម្លាំងពលំមួយដ៏អស្ចារ្យដល់អនុជនជំនាន់ក្រោយឱ្យយល់ថា អម្បូររបស់ខ្លួននោះ ជាអម្បូរខ្ពស់ ជាអម្បូរធ្លាប់មានមហិទ្ធិឫទ្ធិ សែន្យានុភាព ជាអម្បូរដែលប្រវត្តិសាស្ត្រប្រាប់ថា មានអារ្យធម៌ វប្បធម៌លូតលាស់មុន

គេ នៅអាស៊ីអាគ្នេយ៍ឬអាចនៅអាស៊ីនេះតែម្តង! ដូចតទៅនេះ ៖

ប្រទេសឥណ្ឌាដែលមានការផ្លាស់ប្តូរ ច្របូកច្របល់ វឹកវរជាញឹកញយ នោះ បានធ្វើឱ្យអម្បូរខ្មែរបែកបាក់រត់ភៀសខ្លួនទៅនៅរាត់រាយតាមកន្លែងនានា តាំងពីផ្ទៃប្រទេសឥណ្ឌា ដងភ្នំ ដងទន្លេ តាមកោះនានា រហូតដល់អាស៊ីអាគ្នេយ៍ នេះ ប៉ុន្តែលក្ខឋានដែលឃើញច្បាស់ជាចុងបង្អើយនៃការភៀសខ្លួនអំពីប្រទេសឥណ្ឌាមកកាន់អាស៊ីអាគ្នេយ៍ ដូចបានជម្រាបមកតាមលំដាប់អំពីប្រវត្តិសាស្ត្រប្រទេសឥណ្ឌានោះ ក៏ឃើញបានថា នៅសតវត្សរ៍ទី៦ ទី៧ ទី៨ នៃជំនាន់រាជវង្សកុសាណៈ អម្បូរមន-ខ្មែរបានភៀសខ្លួនចេញពីប្រទេសឥណ្ឌា មកតាំងស្រុកទេសនៅលើផ្ទៃដីអាស៊ីអាគ្នេយ៍នេះទាំងអស់។

ការភៀសខ្លួនមកនេះ មិនមែនមកតែខ្លួនទេ គឺថាមាននាំអារ្យធម៌និងវប្បធម៌ដែលខ្លួនធ្លាប់កាន់នោះមកជាមួយផង ហើយបានមកផ្សាយពេញផ្ទៃភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ ទាល់តែមើទៅហាក់ដូចជាប្រទេសឥណ្ឌាទី២តែម្តង! ព្រោះហេតុដូច្នេះ អ្នកប្រាជ្ញល្បីឈ្មោះនានា មានលោក សេដេស៍, ហ្វីល្លិបស្តែននិងលោក ប៉េលីយ៉ុត (Pelliot) ជាដើម បានហៅភូមិភាគអាស៊ីប៉ែកអាគ្នេយ៍ថា អាណាចក្រឥណ្ឌាទៅវិញ ដូចគ្នានឹងប្រជាជនខ្មែរជំនាន់បុរាណរហូតដល់សព្វថ្ងៃ ខ្លះបានហៅស្ថាបត្យកម្ម បដិមាកម្ម ដែលជាថ្វីល្អអស្ចារ្យថា សុទ្ធជាស្នាដៃព្រះឥន្ទ្រទាំងអស់ (ពាក្យថា "ព្រះឥន្ទ្រ" ដែលយើងហៅតាំងពីបុរាណមក គួរឱ្យសន្និដ្ឋានថា "គឺជនជាតិឥណ្ឌា" នោះឯង)។ រីឯនគរផ្សេងៗ ដែលមានឈ្មោះប្រាកដនៅក្នុងដែនដីប្រទេសឥណ្ឌា ដូចជាឥន្ទ្រប្រស្ថ, តក្កសិលា, កម្ពោជៈ, អមរ-វតី, ចាម្ប៉ា, ទ្វារវតី, ក្លិង្គ ក៏ត្រូវបានពួកអម្បូរមន-ខ្មែរ នាំមកនៅតាមកន្លែងនានាដែលខ្លួនបានមកកសាងឥទ្ធិពលថ្មីដែរ។

ពួកអម្បូរមន-ខ្មែរ ដែលរត់ពីក្រុងឥន្ទ្រប្រស្ថ មកនៅលើដងទន្លេមុនា ជិតក្រុងដែល្លីសព្វថ្ងៃនេះ បានមកតាំងក្រុងឥន្ទ្រប្រស្ថលើផ្ទៃដីលាវ ត្រង់ព្រំដែន

សត្វថ្ងៃ ហៅថា ប៉ាកហិនបូរ ឆ្មេរខាងកើតទន្លេមេគង្គ។ គួរឱ្យជឿថា កុលសម្ព័ន្ធនៅក្នុងប្រទេសលាវ គង់មានតំណពីពូជឥន្ទ្រប្រស្ថ:

| | | |
|---|---|---|
| លូវិន (Loven) | ស៊ក (Sork) | លាម៉េត (Lamet) |
| សាពួន (Sapuan) | ង៉េះ (Ngeh) | ថាប (Thap) |
| ង៉ុងបូរ (Ngung Bo) | តៅអយ (Tou oi) | ញ៉ាហិន (Nha Heun) |
| ថឺ (The) | ពូណយ (Pü Noi) | វ៉ិន (Ven) |

(មាននៅត)

ដកស្រង់ដោយៈ ថាច់ សុតឹម

http://nakrean168.blogspot.com/
www.facebook.com/nakrean168